# ព័ត៌មានស្ដីពី
# កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន

កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន របស់សិល្បៈខ្មែរអមតៈ ផ្ដល់អាហារូបករណ៍ ២ ប្រភេទ៖

## ១. អាហារូបករណ៍អភិវឌ្ឍន៍ជំនាញសិល្បៈ

បណ្ដុះបណ្ដាលជំនាញសិល្បៈកម្រិតអាជីព ដូចជា ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងហ្វឹកហាត់ជាមួយគ្រូសិល្បៈឯកជនទាំងផ្នែកបុរាណនិងសម័យ អ្នកស្រាវជ្រាវ និងអ្នកមកពីផ្នែកដទៃទៀតនៅក្នុងវិស័យសិល្បៈនិងវប្បធម៌។

## ២. អាហារូបករណ៍អភិវឌ្ឍន៍ជំនាញមិនមែនសិល្បៈ

អភិវឌ្ឍជំនាញមិនមែនសិល្បៈ ដើម្បីជួយអភិវឌ្ឍអាជីពនៅក្នុងវិស័យសិល្បៈនិងវប្បធម៌ដូចជាថ្នាក់បរិញ្ញាបត្រ (សណ្ឋាគារ និងបដិសណ្ឋារកិច្ចទេសចរណ៍ ប្រព័ន្ធផ្សព្វផ្សាយ -ល-) ថ្នាក់អនុបណ្ឌិត ថ្នាក់កុំព្យូទ័រ ភាសាអង់គ្លេសក្រៅម៉ោង ឬពេញម៉ោងជាដើម។

## វគ្គសិក្សានិងរយៈពេលនៃអាហារូបករណ៍៖

| ប្រភេទ | ឈ្មោះអាហារូបករណ៍ | វគ្គសិក្សាដែលអាចស្នើសុំ មានដូចតទៅ | រយៈពេល យូរបំផុត* |
|---|---|---|---|
| ១ | អាហារូបករណ៍អភិវឌ្ឍន៍ ជំនាញសិល្បៈ | ថ្នាក់វិទ្យាល័យ នៅសាលាមធ្យមសិក្សាវិចិត្រសិល្បៈ (ជំនាញ៖ តូរ្យតន្ត្រី, សូនរូប, របាំ, ល្ខោន, សៀក) | ៣ ឆ្នាំ |
| | | ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ជំនាញ៖ តូរ្យតន្ត្រី, សិល្បៈនាដសាស្ត្រ, សិល្បៈសូនរូប) | ៤ ឆ្នាំ |
| | | ហ្វឹកហាត់ជាមួយគ្រូឯកជនក្រៅម៉ោង (ជំនាញ៖ សម្ភោរ, ស្គូត, ប៉ីពក , អក្សរភ្លេង, ព្យាណូ -ល-) | ២ ឆ្នាំ |
| ២ | អាហារូបករណ៍អភិវឌ្ឍន៍ ជំនាញមិនមែនសិល្បៈ | វិទ្យាល័យ | ៣ ឆ្នាំ |
| | | ភាសាអង់គ្លេសទូទៅ (វគ្គក្រៅម៉ោង, ពេញម៉ោង) | ៣ ឆ្នាំ |
| | | ជំនាញកុំព្យូទ័រទូទៅ | ១ ឆ្នាំ |
| | | មហាវិទ្យាល័យ (ជំនាញ៖ ភាសាអង់គ្លេស, បដិសណ្ឋារកិច្ច និង ទេសចរណ៍, គណនេយ្យ -ល-) | ៤ ឆ្នាំ |
| | | អនុបណ្ឌិត (ជំនាញ៖ បុរាណវិទ្យា -ល -) | ២ ឆ្នាំ |

* ការផ្ដើមអាហារូបករណ៍មានរយៈពេល១ ឆ្នាំ។ អាហារូបករណ៍របស់បេក្ខជនជ័យលាភី នឹងបន្តជារៀងរាល់ឆ្នាំ ដោយយោងទៅតាមលទ្ធផលនៃការសិក្សារបស់បេក្ខជន និង រយៈពេលយូរបំផុតដែលបានបញ្ជាក់ជូនខាងលើ។ សិល្បៈខ្មែរអមតៈ នឹងពិចារណាពាក្យស្នើសុំអាហារូបករណ៍ទាំងពីរប្រភេទ។ ពាក្យស្នើសុំវគ្គសិក្សាណាដែលមិនមាននៅក្នុងបញ្ជីនៃវគ្គសិក្សាដែល

អាចស្នើសុំខាងលើ (<u>ដូចជា៖ ស្រាវជ្រាវ ។ល។</u>) នឹងត្រូវពិចារណាផងដែរ ដរាបណាបេក្ខជនអាចពន្យល់ពីវគ្គសិក្សានោះ ទាក់ទងនឹងអាជីពនៅក្នុងវិស័យសិល្បៈ និងវប្បធម៌។ សិល្បៈខ្មែរអមតៈ ក៏មានមូលនិធិខ្លះសម្រាប់ជួយក្នុងការទិញ ឧបករណ៍ភ្លេង ចំពោះបេក្ខជនស្នើសុំវគ្គសិក្សាហ្វឹកហាត់ជាមួយគ្រូឯកជនក្រៅម៉ោង។

## តើនរណាអាចដាក់ពាក្យស្នើសុំអាហារូបករណ៍នេះបាន?

សិល្បករអាជីព លោកគ្រូ អ្នកគ្រូសិល្បៈ និង អ្នកធ្វើការក្នុងវិស័យសិល្បៈនិងវប្បធម៌ (អ្នកមិនមែនជាសិល្បករ តែធ្វើការ ក្នុងវិស័យសិល្បៈ និងវប្បធម៌ ដូចជា ផលិតករ អ្នកគ្រប់គ្រង អ្នករចនាពិព័រណ៍ អ្នកស្រាវជ្រាវ អ្នកនិពន្ធ -ល-) ដែលមកពី គ្រប់ទម្រង់សិល្បៈទាំងបុរាណទាំងសម័យ។

## តើអ្នកត្រូវមានលក្ខខណ្ឌដូចម្តេចខ្លះដើម្បីអាចដាក់ពាក្យបាន?

- ត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ
- ជាជនជាតិខ្មែរ ឬមានសញ្ជាតិខ្មែរ
- រៀនសិល្បៈខ្មែរបុរាណ ឬសម័យ ឬទម្រង់សិល្បៈដទៃទៀត ដូចជា របាំ ចម្រៀង ភាពយន្ត ស្ថាបត្យកម្ម ចម្លាក់ និង គំនូរជាដើម ឬសិល្បៈដទៃទៀតយ៉ាងតិច៣ឆ្នាំ ឬមានបទពិសោធន៍ការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ យ៉ាង តិច៣ឆ្នាំ។

## តើអ្នកនឹងទទួលបានផលប្រយោជន៍អ្វីខ្លះពីកម្មវិធីអាហារូបករណ៍នេះ?

- ការកសាងសមត្ថភាពតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលគុណតម្លៃ សម្រាប់ការអភិវឌ្ឍខ្លួន ភាពជាអ្នក ដឹកនាំ និងអាជីពការងារ
- ឱកាសចូលរួមទស្សនកិច្ចសិក្សា សិក្ខាសាលា ព្រឹត្តិការណ៍សិល្បៈ និងគម្រោងស្ម័គ្រចិត្តនានា
- ជំនួយផ្នែកស្មារតី និងការប្រឹក្សាយោបល់ពីក្រុមការងារសិល្បៈខ្មែរអមតៈ
- ប្រាក់ឧបត្ថម្ភការសិក្សា ១៥០០ ដុល្លារ ក្នុង១ឆ្នាំ

## តើអាហារូបករណ៍នេះបើកទទួលពាក្យនៅពេលណា?

អាហារូបករណ៍នេះបើកទទួលពាក្យស្នើសុំនៅរៀងរាល់ខែមីនានិងឈប់ទទួលពាក្យនៅចុងខែឧសភា។ ដូចនេះអ្នកមាន រយៈពេល៣ខែសម្រាប់ការដាក់ពាក្យ។

## តើធ្វើដូចម្តេចដើម្បីទទួលបានព័ត៌មានពីកម្មវិធីអាហារូបករណ៍?

ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.cambodianlivingarts.org/arn-chorn-pond-livng-arts-scholarship/
អ៊ីម៉េល៖ sormanak@cambodianlivingarts.org
ទទួលពាក្យស្នើសុំ និងផ្ញើត្រឡប់មកវិញនៅអង្គការសិល្បៈខ្មែរអមតៈដែលមានអាសយដ្ឋាននៅ ផ្ទះលេខ១២៨G៩ ផ្លូវ សុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ តាមរយៈ លោក ឥន្ទ សម៉ាណាក់ អ្នកសម្របសម្រួល កម្មវិធី អភិវឌ្ឍន៍សិល្បៈ ០១០ ៩៤១ ២២៤ ។

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា សង្គមសេដ្ឋកិច្ច និងសហគមន៍ដែលមានសំឡេងតិចឡើយ។ ប្រសិនបើបេក្ខជនដែលមានពិការភាពមានការលំបាកក្នុង ការបំពេញពាក្យស្នើសុំ អាចថតជាវីដេអូផ្ញើមក ឬទាក់ទងមកលេខទូរស័ព្ទ ០១០ ៩៤១ ២២៤ សម្រាប់ព័ត៌មានបន្ថែម។